សម្ភាសន៍ជាមួយឈ្មោះ អៀ ស៊ាន់ ភេទប្រុស អាយុ៥៨ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ មេពួក, ទ័ពអាកាសផ្នែកខាងជាង

មុខងារបច្ចុប្បន្នៈ កសិករ

ស្រុកកំណើតនៅភូមិទឹកចេញ ឃុំត្រពាំងរាំង ស្រុកឈូក ខេត្តកំពត

សព្វថ្ងៃរស់នៅភូមិត្រពាំងវែង ឃុំត្រពាំងរាំង ស្រុកជុំគិរី ខេត្តកំពត

ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ឡុង ដានី និង វ៉ាន់ថាន់ ពៅដារ៉ា

០០:២៤:៣៣

១០ទំព័រ

ដានី ៖ ចឹងជំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ ឈ្មោះពេញឈ្មោះអីដែល?

ស៊ាន់ ៖ ឈ្មោះចឹងម៉ង ។

ដានី ៖ ឈ្មោះថាមេច? ឈ្មោះអៀ ស៊ាន់?

ស៊ាន់ ៖ បាទ!

ដានី ៖ សព្វថ្ងៃពូអាយុប៉ុន្មានហើយ?

ស៊ាន់ ៖ ៥៨ឆ្នាំ ។

ដានី ៖ ស្រុកកំណើតកើតជាពូនៅក្នុងភូមិ ឃុំ ស្រុកអីដែល?

ស៊ាន់ ៖ នៅក្នុងស្រុកឈូកពីដើមណា ។

ដានី ៖ ពីដើមមកភូមិអីដែល?

ស៊ាន់ ៖ ពីដើមភូមិទឹកចេញ ។

ដានី ៖ ឃុំត្រពាំងរាំង?

ស៊ាន់ ៖ បាទ!

ដានី ៖ ស្រុកឈូកហ៊ ពីដើមមក? ខេត្តកំពត?

ស៊ាន់ ៖ បាទ! ស្រុកឈូក ។

ដានី ៖ ចឹងសព្វថ្ងៃពូរស់នៅក្នុងភូមិ ឃុំ ស្រុកអីដែលសព្វថ្ងៃណឹង ?

ស៊ាន់ ៖ សព្វថ្ងៃណឹង រស់នៅក្នុងស្រុកជុំគិរី ។

ដានី ៖ ភូមិអី?

ស៊ាន់ ៖ ភូមិត្រពាំងវែង ឃុំត្រពាំងរាំង ។

ដានី ៖ ឥឡូវភូមិត្រពាំងវែងសព្វថ្ងៃនេះ?

ស៊ាន់ ៖ បាទ!

ដានី ៖ ឃុំត្រពាំងរាំងដដែល?

ស៊ាន់ ៖ បាទ!

ដានី ៖ ស្រុកជុំគិរី? ចុះប្រពន្ធពូគាត់ឈ្មោះអីដែល?

ស៊ាន់ ៖ ឈ្មោះ អែម សាមិត្ត ។

ដានី ៖ សព្វថ្ងៃគាត់អាយុប៉ុន្មានដែល?

ស៊ាន់ ៖ អាយុ៥៧ ។

ដានី ៖ ពូមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែល?

ស៊ាន់ ៖ កូន៥ នាក់ ។

ដានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ស៊ាន់ ៖ ស្រី២ ប្រុស៣ ។

ដានី ៖ សព្វថ្ងៃពូប្រកបមុខរបរកស៊ីធ្វើអីដែល?

ស៊ាន់ ៖ ធ្វើស្រែតែមួយមុខណឹង ។

ដានី ៖ ឪពុកពូគាត់អីទៅ?

ស៊ាន់ ៖ ឈ្មោះអ៊ុក គួន ។

ដានី ៖ សព្វថ្ងៃគាត់នៅរស់ឬក៏?

ស៊ាន់ ៖ ស្លាប់ ។

ដានី ៖ ចុះម្ដាយ?

ស៊ាន់ ៖ ម្ដាយ ខៀវ ណាន់ (ស្លាប់) ។

ដានី ៖ ពូមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់?

ស៊ាន់ ៖ ទាំងអស់ ៧នាក់ ។

ដានី ៖ ប្រាំពិល ឬប្រាំបី?

ស៊ាន់ ៖ ប្រាំពិលនាក់ ។

ដានី ៖ ប្រាំពិលនាក់ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

សាន់ ៖ ស្រី៣ ប្រុស៤ ។

ដានី ៖ ពូកូនទីប៉ុន្មាន?

សាន់ ៖ ខ្ញុំកូនទី៣ ហើយ ។

ដានី ៖ ចុះពូកាលពីក្មេងៗពូបានរៀនសូត្រអីដែលទេ?

សាន់ ៖ រៀន រៀនដល់ថ្នាក់ទី៧ សម័យសង្គម ។

ដានី ៖ ដល់ថ្នាក់ទី៧ រៀននៅណាទៅ?

សាន់ ៖ រៀននៅអង្គចក ។

ដានី ៖ នៅវត្តអង្គចកហ៎?

សាន់ ៖ បាទ!

ដានី ៖ ពូចូលរៀននៅឆ្នាំណា?

សាន់ ៖ ខ្ញុំចូលរៀននៅឆ្នាំ៥៣ ១៩៥៣ ហ៊ឺម៉ានទេ… ៦៣ ។

ដានី ៖ ឆ្នាំ៦៣ ហេ?

សាន់ ៖ បាទ!

ដានី ៖ ហើយឈប់នៅឆ្នាំណា?

សាន់ ៖ ឈប់នៅឆ្នាំ១៩៧០ ។

ដានី ៖ ឈប់ពេលរដ្ឋប្រហារណឹងហ៎?

សាន់ ៖ បាទ!

ដានី ៖ ពេលពូឈប់រៀនហើយពូធ្វើអីទៀតទៅ?

សាន់ ៖ នៅផ្ទះ ។

ដានី ៖ នៅផ្ទះធ្វើអីខ្លះទៅ?

សាន់ ៖ ធ្វើស្រែ ជួយធ្វើការឪពុកម្ដាយមើលគោមើលក្របីណឹង ។

ដានី ៖ ពូនៅធ្វើស្រែជាមួយឪពុកម្ដាយរហូតដល់ពេលណាទៅបានពូចេញទៅទៀត?

សាន់ ៖ ចេញទៅទៀតនៅឆ្នាំ១៩៧៣ ។

ដានី ៖ នៅឆ្នាំ១៩៧៣ ហេពូ?

សាន់ ៖ ចុងឆ្នាំ៧២ ៧៣ ។

ដាវ៉ា ៖ ពូចេញទៅណាណឹង?

សាន់ ៖ ធ្វើទាហាន ។

ដារ៉ា ៖ ចូលទ័ពខ្មែរក្រហមណឹងហេ?

ស៊ាន់ ៖ កាលណឹងសម្ដេចមានប្រកាស់ពីក្រៅឲ្យចូលព្រៃម៉ាកគីដើម្បីតស៊ូភាគច្រើនគឺចូលម៉ង់ ។

ដារ៉ា ៖ ឲ្យតែលឺថាបន្ទាប់ពីលឺការអំពាវនាវណឹងគ្រប់គ្នាចូលម៉ង់?

ស៊ាន់ ៖ ណឹងហើយលន់ នល់ធ្វើរដ្ឋប្រហារគេចូលគ្រប់ៗតែគ្នាយុវជនម៉ាភូមិៗអស់ហើយ គ្មានបន្ទុំទេ ឃាត់មិនឈ្នះទេទៅម៉ង់ ។

ដារ៉ា ៖ ចូលរបៀបទឹកបាក់ទំនប់យ៉ាងមេច?

ស៊ាន់ ៖ បាទ អានេះអំពើរបស់ លន់ នល់ គ្រាន់រដ្ឋប្រហារហើយវានាំគ្នាជិះមកកាន់ស្រុកជុំគិរីមក ត្រពាំងរាំង រថក្រោះវាបាញ់ វាចាប់មាន់ចាប់ទាយើងម៉ាសេរីម្លោះហើយវាឈឺចិត្តតាមអំពាវនាវរបស់សម្ដេចសីហនុ ចេះធ្វើទៅមួយៗ ។

ដារ៉ា ៖ តែនៅកន្លែងស្រុកនេះគេហៅតំបន់ដាច់ស្រយាលដែលយ៉ាងមេចមានទាហានលន់ នល់ ទាហានធៀវគឺចូលមកដល់លុកលុយសម្បើមម្លេះ?

ស៊ាន់ ៖ មកតាមរថក្រោះ នេះជាទីរួមឃុំមួយដែលសំខាន់ដែលម្លោះហើយវាម៉ោម្ដងៗចូលដល់ ។

ដារ៉ា ៖ ចឹងដល់ពេលពូចូល ទៅកាលមុនដំបូងជាទ័ពចឹងម៉ង់ឬជាឈ្លបភូមិ?

ស៊ាន់ ៖ ឈ្លបឃុំអឺ... ឈ្លបស្រុក ។

ដារ៉ា ៖ កាលណឹងគេហៅស្រុកអី?

ស៊ាន់ ៖ ស្រុកឈូក ។

ដានី ៖ ចឹងពូចូលដំបូងធ្វើទ័ពឈ្លបស្រុកឈូក?

ស៊ាន់ ៖ បាទ!

ដានី ៖ កាលណឹងទីកន្លែងទីស្នាក់ការស្រុកឈូកគេនៅណាទៅ?

ស៊ាន់ ៖ មិនដឹងនៅត្រង់ណាទេ គេហៅទៅទៅម៉ង់ មិនដឹងនៅត្រង់ណាផង ។

ដានី ៖ ពីព្រោះកាលណឹងវាចេះរដ្ឋប្រហារ៧០ហើយវារបប លន់ នល់ ចឹងនៅខាងស្រុកឈូកណឹង លន់ នល់គេគ្រប់គ្រងឬខាងរំដោះ?

ស៊ាន់ ៖ ខាងខ្មែរក្រហមគ្រប់គ្រង ។

ដានី ៖ គ្រប់គ្រងទាំងស្រុកឈូកតាមថ្នាល់ជាតិដែល?

ស៊ាន់ ៖ បាទ ខាងថ្នល់ជាតិដាច់អស់ហើយនៅតែកំពត តាកែវហួសអង្គសោមទៅ ។

ដានី ៖ ចុះពូកាលចូលកងទ័ពស្រុកឈូកណឹងមានគ្នាប៉ុន្មាននាក់ដែរដែលនៅកងទ័ពណឹង?

ស៊ាន់ ៖ កងទ័ពណឹងមានម៉ាកងហា អូ!កងវរយ ។

ដានី ៖ គ្នាប៉ុន្មាននាក់ទៅកងរយណឹង?

ស៊ាន់ ៖ មិនដឹងប៉ុន្មានទេ វាត្រូវពាកងហា ម៉ាក្រុមវា១២ ។

ដានី ៖ ចុះពីស្រុកភូមិយើងទៅមានគ្នាប៉ុន្មាននាក់ចូលទៅស្រុកឈូកណឹង?

ស៊ាន់ ៖ ម៉ាស្រុកខ្ញុំណឹងដូចជាអត់មានទេ ក្រោយៗមកបានគេទៅច្រើនម៉ង ក្រោយមកគេទៅច្រើនណាស់ទៅទាំងអស់ ។

ដានី ៖ ចឹងនៅស្រុកភូមិពូនេះពូចូលមុនគេ?

ស៊ាន់ ៖ បាទ!

ដានី ៖ កាលណឹងមានគេមកឃោសនានៅតាមស្រុកភូមិណឹងគេមកឃោសនាកាលជំនាន់ពូចូលណឹង?

ស៊ាន់ ៖ កាលឆ្នាំ៧០មានតែខ្មែរក្រហមណឹងឃោសនាខ្មែរក្រហម ហើយក្រោយមកទៀតមានកងទ័ពវៀតណាម ខ្មែរនៅក្នុងកងទ័ពវៀតណាមពាក់កណ្តាលអីចឹង ទៅគេចេះជួយថាជួយអីចឹងទៅដល់ចឹងមួយៗចង់ធ្វើទ័ពដែល ។

ដានី ៖ ចុះពូនៅពេលពូទៅនៅកន្លែងកងទ័ពស្រុកឈូកណឹងពីណាគេទៅប្រធានកងទ័ព?

ស៊ាន់ ៖ ប្រធានកងទ័ពឈ្មោះអីវុធទេ មិនដឹងជីតាគេស្អីទេខ្ញុំមិនដឹងដែល ឈ្មោះវុធ ។

ដានី ៖ ពូដូចថាយើងចូលទៅកងទ័ពណឹង ដូចយើងមានហាត់រៀនក្បួនយុទ្ធសាស្ត្រកងទ័ពរៀនពីនយោបាយយ៉ាងមេចខ្លះ ទៅពូពេលយើងចូលទៅដំបូងណា?

ស៊ាន់ ៖ ចូលទៅដំបូងហាត់រៀនក្បួនកងទ័ព ៣ខែហាត់៣ខែ បានគេឲ្យឡើងទៅប្រចាំនៅក្បែរកំពតនេះតែប៉ុណ្ណឹង ។

ដានី ៖ ទៅប្រចាំក្បែរកំពតណឹងនៅទ័ពស្រុកដដែលឬក៏...?

ស៊ាន់ ៖ បាទ ទ័ពស្រុកដដែល ។

ដានី ៖ ទៅប្រចាំធ្វើអីនៅណឹង?

ស៊ាន់ ៖ ចាំវ៉ៃកងទ័ពលន់ នល់ចេះដើរពាតក្បាត ។

ដានី ៖ នៅក្នុងកងរយរបស់ពូដដែលកងទ័ពស្រុកណឹង?

ស៊ាន់ ៖ បាទ!

ដានី ៖ ចុះទៅវ៉ៃណឹងវ៉ៃយ៉ាងមេចខ្លះទៅបានវ៉ៃជាមួយលន់ នល់ យើងបាញ់គ្នាអីដែលឬក៏គ្រាន់តែត្រៀម ទេ?

ស៊ាន់ ៖ អត់ដែល អាណឹងត្រៀមចាំ ដូចថាត្រៀមចាំកន្លែងណាចឹងទៅដីវាចែកគ្នា ឬក៏ចាំពួកលន់ នល់វាដើរពាតក្បាតតាមភូមិវ៉ៃឈ្លបអីចឹងទៅ ។

ដារ៉ា ៖ ចុះពូកាន់កាំភ្លើងអីគេ?

ស៊ាន់ ៖ អាកា ។

ដានី ៖ ពូនៅកងទ័ពស្រុកបានរយៈពេលប៉ុន្មានដែល?

ស៊ាន់ ៖ នៅកងទ័ពស្រុកណឹងមិនដឹងប៉ុន្មានទេ មិនដឹងប៉ុន្មានខែមិនចាំដែល ហើយពីណឹងទៅឡើងទៅភាគម៉ង់ ។

ដានី ៖ ឆ្នាំណាដែលពូឡើងទៅភាគណឹង?

ស៊ាន់ ៖ ឆ្នាំ៧៣ ខែ៩ ។

ដានី ៖ ខែប៉ុន្មាន?

ស៊ាន់ ៖ ខែ៩ ខែជិតភ្ជុំហើយ ។

ដានី ៖ ឡើងទៅយ៉ាងមេច ពូឡើងទៅភូមិភាគឡើងទៅ បានន័យថាចូលទៅកងពលម៉ាណអីម៉ាណទៅរបស់ភូមិភាគ?

ស៊ាន់ ៖ បាទ! កងពលដឹងថាកងពលទី១ហើយ ។

ដានី ៖ ឡើងទៅកងពលទី១ភូមិភាគនិរតី?

ស៊ាន់ ៖ បាទ!

ដានី ៖ ពូយ៉ាងមេច បានគេដំឡើងពូពីកងទ័ពស្រុកឈូក ទៅកងពលទី១?

ស៊ាន់ ៖ អាណឹងចឹងម៉ង់ ដល់ទ័ពលើងពីក្រោមទៅគេរុញអាលើទៅលើទៀតណាអាណឹងវាចឹង ។

ដានី ៖ កាលណឹងនៅកន្លែងណាទៅកងពលទី១របស់ពូ?

ស៊ាន់ ៖ កងពលទី១កាលណឹង នៅមុំផ្លូវជាតិលេខ៣នេះបានប៉ុន្មានខែ ឡើងទៅផ្លូវជាតិលេខ៥ម៉ង់ ។

ដានី ៖ កាលណឹងពូនៅក្នុងអង្គភាពអីខ្លះទៅដូចថានៅក្នុងកងហា កងរយ វរសេនាតូច វរសេនាធំលេខប៉ុន្មានមានចាំទេ?

ស៊ាន់ ៖ វរសេនាធំមិនដឹងទីប៉ុន្មានទេ ភ្លេចអស់ហើយយូរពេកហើយ បើកងរយកងរយទី១ ។

ដានី ៖ ចុះពូមានតួនាទីអីដែលកាលណឹង?

ស៊ាន់ ៖ អត់ទេ កាលនៅកងទ័ពហ៎?

ដានី ៖ បាទ!

ស៊ាន់ ៖ ខ្ញុំមេពួក ៣នាក់ ។

ដានី ៖ ចុះកាលណឹងគណៈកងពលទី១ឈ្មោះអីដែល?

ស៊ាន់ ៖ គណៈកងពលទី១ស្អីទេភ្លេចហើយ ។

ដានី ៖ មានឈ្មោះថាមិត្តអីទេ?

ស៊ាន់ ៖ តាមិត្តអត់ដឹងផង ។

ដារ៉ា ៖ ចុះពេលឡើងមកជាទ័ពស្រុកនេះពូមានឋានៈអីដែលចឹង?

ស៊ាន់ ៖ យុទ្ធជននៅកងទ័ពស្រុក ។

ដារ៉ា ៖ កងទ័ពស្រុកជាយុទ្ធជនទេ?

ស៊ាន់ ៖ បាទ!

ដារ៉ា ៖ អត់មានបានមេពួកទៀតទេចុះ?

ស៊ាន់ ៖ អត់ ។

ដារ៉ា ៖ ចុះឡើងមកដល់ទ័ពភូមិភាគនេះជាស្អីវិញ?

ស៊ាន់ ៖ ឡើងមកភូមិភាគខ្ញុំបានធ្វើជាមេពួក៣នាក់ណឹង ។

ដារ៉ា ៖ ដល់ពេលឡើងមកភាគបានជាមេពួកវិញ?

ស៊ាន់ ៖ បាទ!

ដានី ៖ កាលណឹងកងទ័ពនៅភូមិភាគនិរតីមានប៉ុន្មានកងពលទៅ?

ស៊ាន់ ៖ ខ្ញុំមិនសូវដឹងដែរ កងពលទី១ ទី២ មាន២ទេហេ មិនសូវដឹងដែរមិនដឹងមានប៉ុន្មានកងពលទេ ។

ដានី ៖ ចុះគណៈកងពលរបស់ពូពូអត់ស្គាល់គាត់ទេ?

ស៊ាន់ ៖ គណៈកងពលកាលណឹងភ្លេចហើយ តាអីទេភ្លេចហើយ ។

ដារ៉ា ៖ ចឹងពូពេលដល់ឆ្នាំវ៉ៃចូលដល់ភ្នំពេញពូមានបានចូលរួមវ៉ៃចូលភ្នំពេញដែល?

ស៊ាន់ ៖ កាលណឹងខ្ញុំត្រូវរបួសតាំងពីឆ្នាំ ខែប៉ុន្មានទេវ៉ៃដំបូងណា អើវ៉ៃដំបូងវ៉ៃថ្ងៃទី១ណឹងគឺខ្ញុំត្រូវរ
បួសហើយត្រូវរបួសនៅផ្លូវជាតិលេខ៥ ត្រូវរបួសនៅពេទ្យរបួសពិការម៉ង ។

ដានី ៖ ត្រូវរបួសកន្លែងណាទៅពូ?

ស៊ាន់ ៖ ត្រូវស្លូត អំបែងចូលស្លូត ពិការរហូតគ្មានបានវ៉ៃទេ ។

ដារ៉ា ៖ តាំងពីណឹងមក តាំងពីត្រូវរបួសស្លូតមកលែងបានធ្វើទ័ព?

ស៊ាន់ ៖ ពិការរហូត ។

ដារ៉ា ៖ នៅធ្វើទ័ពដដែលឬយ៉ាងមេច?

ស៊ាន់ ៖ នៅក្នុងជួរទ័ពតែនៅគេក្រោយចឹងទៅមិនដែលបានឡើងវ៉ៃ ។

ដារ៉ា ៖ នៅក្រោយពេលដែលបែកភ្នំពេញហើយណឹងហេ?

ស៊ាន់ ៖ នៅពេលគេកំពុងវ៉ៃនៅកន្ទែងបាយនៅក្រោយគេចឹងទៅថៃរបួសអីចឹងទៅ ដូចថាធ្វើការវាមិនកើតពិការចឹងណា ។

ដារ៉ា ៖ ពេលក្រោយមកពេលបែកភ្នំពេញហើយ ចង់និយាយថាខ្មែរក្រហមទទួលបានជ័យជម្នះហើយ ១៧ មេសា ៧៥ណឹងណាពេលណឹងពូត្រូវបានផ្ទេរទៅណាអីទៀត?

ស៊ាន់ ៖ ខ្ញុំក្រោយបែកណឹងគេផ្ទេរឲ្យមកនៅពោធិ៍ចិនតុង ។

ដារ៉ា ៖ នៅណឹងធ្វើអីវិញ?

ស៊ាន់ ៖ ខាងជាងខាងអី ។

ដារ៉ា ៖ ជាងអីគេពូ?

ស៊ាន់ ៖ ជាងយន្តហោះ ជាងឃ្លាំងអីណឹង ។

ដារ៉ា ៖ នៅពោធិ៍ចិនតុងណឹង?

ស៊ាន់ ៖ បាទ!

ដារ៉ា ៖ ចឹងគេហៅទ័ពអី? ទ័ពអាកាស?

ស៊ាន់ ៖ ទ័ពអាកាសពីដើម ។

ដារ៉ា ៖ ចឹងកាលណឹងក្រោមគ្រប់គ្រងរបស់ពីណាគេ?

ស៊ាន់ ៖ តាម៉េត ។

ដារ៉ា ៖ តាម៉េត?

ស៊ាន់ ៖ បាទ!

ដារ៉ា ៖ ចឹងតាម៉េតគាត់នៅពោធិ៍ចិនតុងទីបញ្ជាការរបស់គាត់?

ស៊ាន់ ៖ មិនដឹងនៅត្រង់ណាទេដែលឃើញគាត់ចុះទៅម្តងៗទីបញ្ជាការគាត់មិនដឹងត្រង់ណាត្រង់ណី មិនដឹងដែលមិនដឹងគាត់នៅផ្សារ ឬគាត់នៅត្រង់ណាផ្សារពោធិ៍ចិនតុងក៏មិនដឹង ឬក៏ភ្នំពេញក៏មិនដឹង អត់ដឹងដែល ។

ដារ៉ា ៖ ចឹងពូមកនៅពោធិ៍ចិនតុងជាទ័ពអាកាសណឹងធ្វើជាងវិញ?

ស៊ាន់ ៖ ធ្វើជាង ។

ដារ៉ា ៖ ជាងជួសជុលអីខ្លះទៅ?

ស៊ាន់ ៖ ខ្ញុំជួសជុលនាឡិកា ជួសជុលភ្លើងអគ្គីសនី ។

ដារ៉ា ៖ ពេលណឹងឃើញសភាពម៉េចដែលនៅពេលដែលធ្វើទ័ពអាកាសណឹង?

ស៊ាន់ ៈ  អត់មានអីដែលសភាពធូរស្រាលខ្ញុំមិនដឹងថានៅខាងក្រោយញាប់ជាងខាងមុខផង  នៅខាងមុខធូរស្រាលធម្មតាដើរ  ប៉ុន្តែយើងធ្វើពលកម្មមួយដងមួយកាលចឹងទៅណាអារឿងអីៗអត់ដឹង ។

ដារ៉ា ៈ  ចុះការប្រជុំជីវភាពអីមានទេ?

ស៊ាន់ ៈ  ប្រជុំជីវភាពមានធម្មតានៅទ័ពក៏ចឹងដែល ។

ដារ៉ា ៈ  រាល់ការប្រជុំគេនិយាយពីអីខ្លះ?

ស៊ាន់ ៈ  និយាយពីការងារដែលយើងបំពេញមួយថ្ងៃៗចឹងទៅមានខុសមានអីលើកឡើងពីណាខុសពីណាត្រូវមានតែប៉ុណ្ណឹង ។

ដារ៉ា ៈ  ពូធ្លាប់បានជ្រើសឲ្យទៅប្រភេទធ្វើមេទ្ធិញធំៗនៅស្ដាតអីទេពូ?

ស៊ាន់ ៈ  ដែល  ទៅស្ដាត  ក្មេងអស់ហើយពូអើយ ។

ដារ៉ា ៈ  នៅកន្លែងពូមានមេៗអីចុះមកផ្សំផ្សាយរឿងការក្បត់ការអីដែល?

ស៊ាន់ ៈ  អត់ដឹង ។

ដារ៉ា ៈ  អត់ដឹង?

ស៊ាន់ ៈ  បាទ!  អត់មានដឹងសោះ  មានតែភ័យ  មានគេចាប់ទីចចាប់នេះទីចចាប់នោះចឹងមានការភ័យរឿងក្បត់អីក៏មិនដឹងៗ ។

ដារ៉ា ៈ  គិតតែពីភ័យរហូតចឹង?

ស៊ាន់ ៈ  បាទ ដឹងតែធ្វើល្អ ។

ដារ៉ា ៈ  ពូនៅណឹងរហូតដល់ពេលបែកភ្នំពេញម្តងទៀតឬក៏យ៉ាងម៉េច?

ស៊ាន់ ៈ  នៅរហូតទាល់បែកភ្នំពេញម្តងទៀត  រត់មករហូត ។

ដារ៉ា ៈ  រត់មកណា?

ស៊ាន់ ៈ  រត់មកខាងលិចភ្នំពេញមក  រត់ដល់ពោធិ៍សាត់ចូលព្រៃ  ចេញពីព្រៃវិញមកផ្ទះ ។

ដារ៉ា ៈ  មកភូមិម៉ង?

ស៊ាន់ ៈ  បាទ!

ដារ៉ា ៈ  ពេលណឹងពូមានគ្រួសារអីនៅ?

ស៊ាន់ ៈ  នៅទេ ។

ដារ៉ា ៈ  អត់ទាន់មានគ្រួសាទេ  ចឹងពូបានគ្រួសារនៅឆ្នាំណា?

ស៊ាន់ ៈ  នៅឆ្នាំ៨២  ឬ៨១ទេការនៅយើងនេះ ។

ដារ៉ា ៈ  ការនៅភូមិ៨២  ៨១ណឹងហេ?

ស៊ាន់ ៖ បាទ!

ដារ៉ា ៖ កាលពីសម័យខ្មែរក្រហមណឹងពូនៅលីវទេ?

ស៊ាន់ ៖ បាទ!

ដានី ៖ ពេលរត់៧៩ពេលយួនចូលណឹង កាលណឹងពូអត់ខ្លាចយើងត្រឡប់មកស្រុកវិញ យួនអាករ វះពោះដូចពាក្យអី ខ្ញុំឮតាមពូមីងម៉ាចំនួនមានការឃោសនាថា អូត្រឡប់មកប្រយ័ត្នយួនចាប់អារវះពោះមានទេ ពាក្យណឹង?

ស៊ាន់ ៖ ដំបូងឮចឹងដែលពាក្យណឹង គំរាមកំហែង ឬក៏ការពិត បើយើងអត់ដឹងដែរ ប៉ុន្តែជាអត់ហ៊ានចូល ដល់យូរទៅដល់អស់ដៃអស់ជើង រកអីមិនបានហូបណឹងម៉ង មានតែឲ្យខ្វះមកស៊ើបៗទៅដល់ឆ្ងាយបានចុះមក ។

ដានី ៖ ចុះមកម៉េចដែល?

ស៊ាន់ ៖ ចុះមកអត់អីដែល ។

ដានី ៖ ពេលពូចុះមកអត់អីចឹងពូមានអារម្មណ៍ម៉េចដែល?

ស៊ាន់ ៖ មានអារម្មណ៍ម៉េចវាធម្មតា ។

ដានី ៖ ចុះមានអារម្មណ៍ថា ពាក្យដែលគេនិយាយពីមុនមកជាត្រឹមត្រូវដែរ ឬក៏មិនត្រឹមត្រូវទេដូចថានិយាយទៅវាយ៉ាងម៉េចទៅ?

ស៊ាន់ ៖ វាមិនចាប់អារម្មណ៍អីរឿងណឹង រឿងណឹងវាថាមួយជានយោបាយ ខ្ញុំមិនចាប់អារម្មណ៍រឿងល្អអាក្រក់ពីដើមមកវាចឹងក៏មិនដឹង ឬវាអត់ក៏មិនដឹងខ្ញុំខ្វិលចាប់អារម្មណ៍ ។

ដានី ៖ ពូមានធ្លាប់មកលេងផ្ទះទេ តាំងពីពូចូលកងទ័ពមកពូនៅពោធិ៍ចិនតុងធ្វើជាងធ្វើអី ពូមានដែលបានមកលេងផ្ទះទេ?

ស៊ាន់ ៖ អត់ដែល អត់ដឹងនៅផ្ទះណឹងយ៉ាងម៉េចយ៉ាងម៉ានៅភូមិ ឃុំណឹងម៉េចអត់ដឹងដែល ។

ដានី ៖ អត់ដែលដឹង?

ស៊ាន់ ៖ បាទ!

ដារ៉ា ៖ ដូចជាអស់សំណួរហើយគាត់ដូចអត់សួរពូអត់សួរនិយាយ ។

ស៊ាន់ ៖ បាទ មិនដឹងនិយាយថាម៉េច ។

ដារ៉ា ៖ ខំប្រឹងសួរអស់ប៉ុណ្ណឹងហើយ ។

ស៊ាន់ ៖ សួរខ្ញុំឆ្លើយៗបើអត់សួរមិនដឹងនិយាយថាម៉េច ។

ដារ៉ា ៖ អរគុណពូច្រើនណា ។

*ស៊ាន់ ៖ បាទ!*

«ចប់»